# សិលាចារឹកប្រាសាទតារស់ K.៣៤៨

## ១- ព័ត៌មានទូទៅ

ប្រាសាទតារស់ ស្ថិតនៅភូមិអូរក្សាន្ត ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានចម្ងាយ៧គីឡូម៉ែត្រ(គ.ម.)ខាងកើតស្រុកជាំក្សាន្ត ៥គ.ម.ខាងកើតភូមិអូរក្សាន្ត និងនៅខាងត្បូងប្រាសាទនាគបួសឬអ្នកបួស។ នៅក្នុងអត្ថបទមុន (សូមអាន៖ https://ams.com.kh/khmercivilization/detail/26178) យើងបានសិក្សាសិលាចារឹកប្រាសាទនេះលេខ K.៣៤៩ ដែលជាអត្ថបទខាងដើម ចំណែកឯអត្ថបទសិលាចារឹក K.៣៤៨ នេះ ជាអត្ថបទចារបន្តដើម្បីបញ្ចប់សេចក្ដី។ ដោយផ្ទាំងនេះជាអត្ថបទបន្ត យើងអាចសន្និដ្ឋានបានថាមានកាលបរិច្ឆេទ មហាសករាជឆ្នាំ៨៧៦ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៥៤ ដូចសិលាចារឹកមុនដែរ។ ចំពោះអត្ថន័យវិញ សិលាចារឹកផ្ទាំងនេះរៀបរាប់ថាដីនៅខាងត្បូងព្រៃផ្ដៅនិងដីនៅខាងត្បូងនោះដែលកាលពីមុនធ្លាប់មានជម្លោះ សភាបានកាត់ក្ដីឱ្យអ្នកព្រះថ្ឍល់ឈ្នះ។ ក្រោយមកទើបស្ដេញអញសិវាចារ្យបានជាវដីទាំងនោះ និងដីមួយចំនួនទៀតពីអ្នកព្រះថ្ឍល់ រួចថ្វាយដល់ប្រាសាទព្រះគម្តែងអញសិវលិង្គវិញ។ អត្ថបទនេះ ក៏រៀបរាប់អំពីទ្រព្យនានាដែលយកទៅជាវដីទាំងនោះផងដែរ។

## ២- អត្ថបទដើមជាអក្សរទំនើប

១- នេះកតិប្រសិរិនាព្វ៖ទ្វារតវ៉្រស្រចិតពោះ

២- ០សិទ្ធិ។ក[១]គិនោះភូមិនោះត[២]ស្រចិតិជៅហោង[៣]ហេតុ[៤]មន្ទា

---

[១] ក្នុងសំណៅផ្តិតគឺ «ក» លោក សេដែស ជួសពាក្យនេះជា «ក[ា]ល»។

[២] លោក សេដែស មិនអានពាក្យ «ត» នោះទេ ព្រោះលោកយល់ថាហាក់ចម្លែកដែលពាក្យនេះនៅខាងដើមពាក្យ «ស្រចិ»។

[៣] លោក សេដែស ថែមពាក្យ «មាន» នៅចន្លោះនេះ បើពុំនោះទេឃ្លាដើមអានជា «ហេតុ» នឹងប្រែថា «ព្រោះ»។

[៤] ពាក្យ «តុ» នេះជួសនៅផ្នែកខាងលើ ចន្លោះ «ហេ» និង «ម»។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

៣- និអបវាទនុអ្នក៑វ្រះថ្បល្វ៑[[វា]]ហារសភាប្រេអ្នក៑វ្រះថ្ប

៤- លិគុទ្វអនក៑វ្រះថ្បលិផ្ទះ[៥]ទេបិស្តេញ៑គិវាចាយ៌្យដោវកូមិត

៥- អនក៑វ្រះថ្បលិតផ្ទះវាបិហ្វូទយតម្រូចិវាបិអាមូលវាបិ

៦- ទាមេធម្ម៌មេបីត៑[៦]នុវក្វនិចៅស្មោង៑វ្នសិផោង្វគី[៧]ទ្រវ្យនុ(វ)[៨]

៧- ដោវរោទិជ្យង៑ប្រាមខលិប្រក៑លិង៑ប្រាមស្មៅក៑ជ្យង៑ប្រម្វាយទៅ

៨- បិម្វាយិផ្នប[៩]ម្វាយចនិល្យក៑វាសិម្វាយយៅប្រាមទៅតមេបិត

៩- នុវក្វនិផោង្វ•ទ្រវ្យតទៅតមេធម្ម៌នុវាបិអាវាបិទាវាបិហ្វូ

១០- ទយនុវស្មោង៑វ្នសិផោង្វនុវក្វនិចៅផោង្វរៅទីជ្យង៑ប្រាម

១១- បទិគះជ្យង៑ប្រាម៑ខលិប្រាកលិង៑ប្រាមមាសបាទម្វាយទៅ

១២- បិម្វាយិថ្នបិរីកត[១០]វ្យរក្របិម្វាយស្រុគតម្វាយកយិវ្យរ

១៣- ឱយហ្វបនុជ្រូក្កនាស្រេមនិដោវស្បង្គឱយផ្ទែករោម៑[១១]

១៤- តវ្រះកម្រតេង៑អញ៑គិវលិង្គឯត៑អបវាទ•មន្វាបិអា

១៥- វាបិហ្វូទយនុវស្មោង៑វ្នសិផោង្វយៅក៑ក្របិវ្រះកំម្រ

១៦- តេង៑អញ៑គិវលិង្គបិឱយិវ្រះស្ថិតីយ[១២]ទៅតខ្ញោញ៑

១៧- វ្រិហស្បង្គសន្មេនិនុវខ្ញោញ៑ឱយិផ្ទែករោមិតិបូវ៌ា

១៨- គ្មេយរល្មុវផ្ទែករោម៑មនិឱយ្ត្តមុហ្នីតវ្រះកម្រតេង៑អ

---

[៥] ពាក្យ «ផ្ទះ» នេះជួសនៅផ្នែកខាងក្រោម ចន្លោះ «ថ្បលិ» និង «ទេបិ»។

[៦] លោក សេដេស និងលោក ចេណ្ណឹរ អានជា «បិត៑» ក្នុងសំណៅផ្តិតគឺ «បីត៑»។

[៧] លោក សេដេស និងលោក ចេណ្ណឹរ អានជា «គិ» ក្នុងសំណៅផ្តិតគឺ «គី»។

[៨] អក្សរមើលមិនច្បាស់ក្នុងសំណៅផ្តិត។ លោក សេដេស និងលោក ចេណ្ណឹរ អានជា «នុ»។

[៩] ពាក្យត្រឹមត្រូវគឺ «ថ្នប» តែចំណារក្នុងសិលាចារឹកនេះគឺអក្សរ «ផ»។

[១០] លោក សេដេស និងលោក ចេណ្ណឹរ អានជា «វិកត» ក្នុងសំណៅផ្តិតគឺ «វីកត»។

[១១] លោក ចេណ្ណឹរ កែអំណានអត្ថបទចារឹកទៅជា «ស្បង់ផ្ទែករោម៑តឱយិ»។

[១២] លោក ចេណ្ណឹរ កែអំណានអត្ថបទចារឹកទៅជា «ស្ថិតីយ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១៩- ញ្ញិគិវលិង្គសិទ្ធិឯតិអបវាទកគិនោះផ្ទែកពោមិ

២០- នោះស្តេញ្ញិអាចាយ្យ៍[១៣]វិធីដៅសោតិតវាបិអាវាបិទា

២១- វាបិហ្វូទយមេជម្ម៌មេបិតនុវស្មោងិវ្ន៌សិក្ធនិចៅផោ

២២- ង្វមា្វយិវត្តនុវស្រែមន្ទោះតវាបិសង្វនុវស្រែនាមា

២៣- (និ)គិទ្រវ្យនុដៅវផ្ទែកពោមិនោះក្របិមា្វយទៅវ្រះស្តិ

២៤- (តីយ)ក្របិមា្វយ(តនុ)[១៤]ចនិល្យកិយោប្រមា្វយនុវល្វ្យលិ

២៥- ----[[ប្រោ]]ក្តនុ[១៥]ស្វោកិធ្នរ[១៦]មា្វយទៅតមេបិតិនុវក្វ

២៦- (និផោង្វ)-----(សវ្វ៌)មាសិបាទមា្វយថ្នបិរិលះមា្វយ

២៧- ----(ប្រមា្វយ)ចនិល្យកិយោវ្យរទ្រវ្យតិដៅតវាបិ

២៨- (អាវាបិទា)វាបិហ្វូទយនុវស្មោងិវ្ន៌ស្មោង្វមាសិបាទវ្យរប

២៩- [[ទិគះមា្វ]][១៧]យធ្នង្វង្កៅវ្យរស្វោកិធ្នរបិយចនិល្យកិវាសិ-

៣០- ---(ប្រមា្វយឱយហ្វបិ)[១៨]នាស្រែមនិដៅវ[១៩]អនកិវ្រះ

៣១- (ថ្បល្វ)ឱយក្វមិនោះតវ្រះកម្រតេងអញ្ញិគិវលិង្គសិទ្ធិ

៣២- ឯតិអបវាទ(ទារផោង)ទ្រវ្យនុដៅវនោះផ្ទែកពោមិនេះ[២០]

៣៣- --លមា្វយិខលិប្រកិបិយិ[២១]វៅទិវ្យរស្វោកិអំរុងិវ្យរ-

---

[១៣] លោក សេដេស និងលោក ចេណ្ណឹរ អានជា «គិវាចាយ្យ៍» ក្នុងសំណៅផ្តិតគឺ «អាចាយ្យ៍»។

[១៤] អក្សរមើលមិនច្បាស់ក្នុងសំណៅផ្តិត។ លោក សេដេស និងលោក ចេណ្ណឹរ អានជា «ក្របិមា្វយិនុ»។

[១៥] លោក សេដេស និងលោក ចេណ្ណឹរ មិនអាន។

[១៦] លោក សេដេស និងលោក ចេណ្ណឹរ អានជា «ធ្នរិ» នៅក្នុងសំណៅផ្តិតគឺ «ធ្នរិ»។

[១៧] លោក សេដេស និងលោក ចេណ្ណឹរ មិនអាន។

[១៨] លោក សេដេស និងលោក ចេណ្ណឹរ អានតែ «យ» ទីមួយប៉ុណ្ណោះ។

[១៩] លោក ចេណ្ណឹរ ថែម «ត» នៅចន្លោះនេះ។

[២០] ក្នុងសំណៅផ្តិតគឺ «នេះ» លោក ចេណ្ណឹរ កែជា «នោះ»។

[២១] លោក សេដេស និងលោក ចេណ្ណឹរ អានជា «បីយិ» នៅក្នុងសំណៅផ្តិតគឺ «បិយិ»។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

៣៤- -----វ្យរឆ្នងលង្តោវ្យរលង្តោស[២២]រាប្លៃបិយ[២៣]

៣៥- ----(ប្រ)បិយ[២៤]ថ្នបិប្វន្នចន្ទ្យក៌វាសិប្រំប្វន្នស្រុគ

៣៦- [ត]រង្គោច្ញូងតបសុរាច្ញូងប្រាមិ៙

## ៣- អត្ថបទប្រែសម្រួល

(១) នេះគឺជាសំណេរនាព្រះទ្វារ[២៥]ដែលពុំទាន់(រួច)ស្រេច។

(២-៦) (សូមបានជា)សេចក្តីសម្រេច! គឺដីនោះ(ដីនៅខាងត្បូងព្រៃផ្តៅនិងដីនៅខាងត្បូងនោះ)[២៦]ដែលបានជាវស្រេចហោង ដោយហេតុមានជម្លោះនឹងអ្នកព្រះថ្យល់ សភា(បានពិនិត្យ)រឿងក្តីក្តាំនេះរកឃើញថាអ្នកព្រះថ្យល់បរិសុទ្ធ។ អ្នកព្រះថ្យល់(ជាអ្នក)ឈ្នះ(ក្តី)។ ទើបស្តេញសិវាចារ្យជាវដីពីអ្នកព្រះថ្យល់ ដែល(មាន)ឈ្មោះវាបហបុទ័យ(ជា)តម្រួតវាបអា(ជា)អ្នកគ្រប់គ្រង វាបទា មេធម្ម៌ មេបិត និងកូនចៅជាអ្នកវាស់វែងសង់(ព្រំដី)ផង។

(៦-៩) ទ្រព្យដែលយកទៅជាវ(មាន) ថូវៅទិ៥ជញ្ជីង ខាត់ប្រាក់៥តម្លឹង ស្លក៦ជញ្ជីង ទោប១ ក្លួយប្ញផាហ៊ុម១ សម្បៀក១វាស់ ៥យោ ឲ្យទៅមេបិតនិងកូនផង។

(៩-១៤) ទ្រព្យឲ្យទៅមេធម្ម៌ វាបអា វាបទា វាបហបុទ័យ និងអ្នកវាស់វែងផង ព្រមទាំងកូនចៅផង (មាន)ថូវៅទិ៥ជញ្ជីង បទិគះ(កន្ថោរស្តោះ)៥ជញ្ជីង ខាលប្រាក់៥តម្លឹងមាស១បាទ ទោប១ ក្លួយប្ញផាហ៊ុមធំ២ ក្របី១(ក្បាល) ស្រូវ១២២ ឲ្យជ្រូកស៊ីនៅស្រែដែលបានជាវ។ ដីទាំងអស់ថ្វាយដល់គម្តែងអញសិវលិង្គដោយមិនមានការជំទាស់។

(១៤-១៩) វាបអា វាបហបុទ័យ និងអ្នកវាស់វែងទាំងឡាយ យកក្របីព្រះគម្តែងអញសិវលិង្គដើម្បីឲ្យគ្រឿងទំនុកបម្រុងព្រះទៅខ្លោញស្រូវ(ប្រធានផ្នែកយកពន្ធស្រូវ) ដោយ

---

[២២] អក្សរមើលមិនច្បាស់ក្នុងសំណៅផ្តិត។ លោក សេដេស និងលោក ចេណ្ណឹរ អានជា «សំ»។

[២៣] លោក សេដេស និងលោក ចេណ្ណឹរ អានជា «បីយិ» នៅក្នុងសំណៅផ្តិតគឺ «បិយិ»។

[២៤] លោក សេដេស និងលោក ចេណ្ណឹរ អានជា «បីយិ» នៅក្នុងសំណៅផ្តិតគឺ «បិយិ»។

[២៥] គឺសិលាចារឹក K.៣៤៩ ដែលនៅមេទ្វារខាងត្បូងនៃប្រាង្គកណ្តាលរបស់ប្រាសាទតារស់។

[២៦] តាមសិលាចារឹក K.៣៤៩ ដីទាំងពីកន្លែងនេះជាវពីវាបហបុទ័យ វាបអា វាបទា តាញធម៌ តាញបិត និងក្រុមគ្រួសារជាអ្នកវាស់វែង។ ក្នុងសិលាចារឹក K.៣៤៨ នេះតាញទាំងពីរមានឋានន្តរនាមថា «មេ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

រួមគ្នាជាមួយខ្ញោញ(ស្រូវ) ជូនដីនៅចន្លោះទិសខាងកើតនិងអាគ្នេយ៍(ដល់ស្ដេញសិវាចារ្យ) និងរាល់ដីដែលបានថ្វាយពីមុននេះដល់ព្រះគម្ដែងអញសិវលិង្គ ថ្វាយសិទ្ធិ(ជាម្ចាស់គ្រប់គ្រង)ដោយមិនមានការជំទាស់។

(១៩-២៣) គឺដីនោះ ស្ដេញអាចារ្យជាវវិញពីវាបអា វាបទា វាបហឫទ័យ មេធម្ម៌ មេបិត និងអ្នករាស់វែងព្រមទាំងកូនចៅផងទាំងឡាយ ដែលពេលជាមួយគ្នានោះស្រែនេះបានលោះពីវាប សងនឹងស្រែដែលមាន។

(២៤-២៧) ទ្រព្យដែលយកទៅជាវដីនោះ(មាន) ក្របី១សម្រាប់គ្រឿងទំនុកបម្រុងព្រះ សម្លៀក៦យៅ ពពិល.. .និងស្ពកតូច១ ឲ្យទៅមេបិត ព្រមទាំងកូនផងទាំងឡាយ... មាស១បាទ កួយឬផាហ៊ុម១បន្ទះ ... សម្លៀក២យៅ។

(២៧-៣២) ទ្រព្យដែលយកទៅជាវពីវាបអា វាបទា និងអ្នករាស់វែងផងទាំងឡាយ មានមាស២បាទ បទិគះ(កន្ធោរស្ពោះ)១ ផ្ទាំងស្ពាន់២ ស្ពកតូច៣ សម្លៀករាស់...៦ ឲ្យស៊ីនៅស្រែដែលបានជាវពីអ្នកព្រះជ្បល់។ ថ្វាយដីនោះដល់ព្រះគម្ដែងអញសិវលិង្គ ថ្វាយសិទ្ធិ(ជាម្ចាស់គ្រប់គ្រង)ដោយមិនមានការជំទាស់។

(៣២-៣៦) (ទទួល)ទ្រព្យជាច្រើនយកទៅជាវដីនោះ(មាន) ខាលប្រាក់៣ ថូវៅទិ២ ស្ពកធំ២ ...២ ផ្ទាំងស្ពាន់២ ស្ពាន់២៣សម្រាប់ ... កួយឬផាហ៊ុម៤ សម្លៀក៩រាស់ ស្រូវ១០០ អង្ករ១០ថ្លឹង សុរា៥ថ្លឹង។

## ៤- វាក្យសព្ទសំខាន់ៗ

| | |
|---|---|
| **ប្រសិរិ** | អ្វីដែលសរសេរហើយ មានអត្ថបទ សំណេរ សិលាចារឹកជាដើម។ |
| **ភូមិ** | ជាពាក្យមកពីសំស្ក្រឹត ដែលន័យដើមគឺ ដី។ |
| **អបវាទ** | ជម្លោះ, ការទាស់ទែង។ |
| **វ្យវហារ** | រឿងក្ដី, ការកាត់ក្ដី។ |
| **ជៅ~ជៅវ** | ជាវ, ទិញ។ |

អត្ថបទដោយៈ ហ៊ុន ឈុនតេង

| | |
|---|---|
| ជ្ទះ > | ឈ្នះ។ |
| ស្មោក៑ | ស្លក។ |
| ធ្មរ៑ | ធ្មារ, តូច។ |
| អំរុង៑ | < រុង៑ "ធំ"៖ ទំហំ, សភាពធំ, រាងរៅឬមាឌដែលធំ។ |
| វល្យលិ | (វលិវ្យលិ) ពពិល។ |
| ស្តិតីយ | អ្វីដែលតាំងនៅ អ្វីដែលទ្រទ្រង់ឲ្យតាំងនៅបន្ត គ្រឿងទំនុកបម្រុង។ |
| ខ្លោញវ្រិហ | ខ្លោញស្រូវ, ប្រធានផ្នែកយកពន្ធស្រូវ។ |
| ថ្នបិ | ផ្ទួយឬផាហ៊ុម។ |
| លង្តៅ | ស្លាន់។ |
| ថ្វង៑ | ជារង្វាល់គ្រាប់ធញ្ញជាតិ ផ្លែឈើ ឬស្រែ[២៧]។ |

## ឯកសារពិគ្រោះ


CISARK

Ta Ros. https://cisark.mcfa.gov.kh/core/showsite.php?id=616&keyword=ta%20ros

Cœdès, G.

1953. Inscription de Pràsàt Tà Rŏs (K. 348, 349) in *Inscriptions du Cambodge*, Vol. 5. Paris.

Jenner, P.

Piédroits of Pràsàt Tà Rŏs in *Part xml, № 41*. http://sealang.net/ok/corpus.htm

Lunet de Lajonquière, É. E.

(1907). Inventaire Descriptif Des Monuments Du Cambodge, Tome Deuxième.


AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

---

[២៧] សូមអាន៖ ពាក្យរង្វាល់ ថ្វង៑ និង ទ្នាលិ ក្នុងភាសាខ្មែរបុរាណ និងកម្លាយរបស់ពាក្យទាំងពីរនេះក្នុងភាសាខ្មែរទំនើប។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

# បញ្ជីរូបភាព



រូបថតប្រាង្គទាំងបីនៃប្រាសាទតារស់ (ប្រភពរូប៖ CISARK)

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



រូបថតសិលាចារឹកប្រាសាទតារស់ K.៣៤៨ (ប្រភពរូប៖ CISARK)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



សំណៅផ្តិតសិលាចារឹកប្រាសាទតារស់ K.៣៤៨ ផ្នែកខាងលើ (រូបថត៖ EFEO ដកពី CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកប្រាសាទតារស់ K.៣៤៨ ផ្នែកខាងក្រោម (រូបថតៈ EFEO ដកពី CISARK)

អត្ថបទដោយៈ ហ៊ុន ឈុនតេង